អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-May-2023, 13:00
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ

ផ្ញើពី: គង់ ស្រីម ប្រធានអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២៣

ផ្ញើជូន: ជា លាង សហព្រះរាជអាជ្ញាជាតិ
Fergal GAYNOR សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង)

ចម្លងជូន: ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល
លោក មុំ លុជ្យ សហមេធាវីការពារក្តីជាតិ
លោក Richard Rogers សហមេធាវីការពារក្តីអន្តរជាតិ
លោក Gôran SLUITER សហមេធាវីការពារក្តីអន្តរជាតិ
លោក ពេជ អង្គ សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី
លោកស្រី Falguni DEBNATH សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល

កម្មវត្ថុ: សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៤/២ (E004/2/7)

**រំលឹកថា** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំធ្វើចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០៤/២ (E004/2/7) ("សំណើសុំ")[1] ដែលក្នុងនោះសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា អង្គបុរេជំនុំជម្រះបានចាត់ទុកអង្គជំនុំជម្រះតុលាការកំពូលជាអង្គជំនុំជម្រះតែមួយគត់ដែលមានលក្ខណៈពេញលេញក្នុងពេលបច្ចុប្បន្នធ្វើចំណាត់ថ្នាក់សំណុំរឿង ០០៤/២ ពីព្រោះអង្គបុរេជំនុំជម្រះពុំបានចេញសេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០៤/២ ឡើយ និងដើម្បីឱ្យឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០៤ និង ០០៤/១ ដែលមានឯកសារជាច្រើនដូចគ្នា និងពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៤/២[2],

**កត់សម្គាល់ថា** សារណាជារួមរបស់សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា វិធីសាស្ត្រទូទៅរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងដំណើរការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញគប្បីថ្លឹងថ្លែងរវាងគោលការណ៍នៃការបើកចំហ ជាមួយនឹងតម្លាភាព ដោយមានកាតព្វកិច្ចការពារសន្តិសុខ និងសិទ្ធិឯកជន និងអត្ថប្រយោជន៍របស់បុគ្គលដែលមានឈ្មោះក្នុងឯកសារទាំងនោះ[3],

**ពិចារណាឃើញថា** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឱ្យធ្វើការរួមចំណែកប្រកបដោយអត្ថន័យពីដំបូងក្នុងដំណើរការនៃការធ្វើចំណាត់ថ្នាក់ឡើងវិញរបស់តុលាការ តាមរយៈការស្នើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញលើឯកសារជាក់លាក់នៃសំណុំរឿង ០០៤/២ និងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការកំណត់សម្គាល់បញ្ហានានា និងបង្កើតគោលនយោបាយដើម្បីធានាថា ការធ្វើចំណាត់ថ្នាក់ឡើងវិញនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.") ត្រូវបានអនុវត្តឡើងដោយមានការប្រុងប្រយ័ត្ន និងស្របគ្នាគ្រប់សំណុំរឿងទាំងអស់[4],

---

[1] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២១ ឯកសារលេខ E004/2/7 ("សំណើសុំ")។

[2] សំណើសុំ (E004/2/7) កថាខណ្ឌ ១៦។

[3] សំណើសុំ (E004/2/7) កថាខណ្ឌ ១-៧។

[4] សំណើសុំ (E004/2/7) កថាខណ្ឌ ១-៧, ១០៨។

**កត់សម្គាល់ថា** វិធីសាស្ត្រដែលបានស្នើឡើងសម្រាប់ការវិភាគ និងការកំណត់ប្រភេទឯកសារដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងការធានាឱ្យមានការយល់ដឹងច្បាស់លាស់នៃទំនាក់ទំនងរវាងឯកសារនានា[5] ព្រមទាំងឧបសម្ព័ន្ធទាំងអស់ផ្សេងៗដែលភ្ជាប់ទៅនឹងសំណើសុំនោះ[6],

**រំលឹកថា** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល"ស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០២"("សេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ")[7] ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣ ដែលអនុម័តសេចក្តីណែនាំទូទៅសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ("សំណុំរឿង ០០២"),

**យោងតាម** មាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ និងការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធសំណុំរឿង (វិសោធនកម្មលើកទី ១) ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ")។ អង្គជំនុំជម្រះតុលាការកំពូលដែលជាអង្គជំនុំជម្រះចុងក្រោយបានទទួលសំណុំរឿង ០០៤/២ បានផ្តួចផ្តើមធ្វើការពិនិត្យរាល់ឯកសារទាំងអស់ដែលមានក្នុងសំណុំរឿងសម្រាប់គោលបំណងនៃការធ្វើចំណាត់ថ្នាក់ស្របតាមសេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដើម្បីរក្សាភាពស្របគ្នាក្នុងការធ្វើចំណាត់ថ្នាក់លើសំណុំរឿងផ្សេងៗ។

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះសម្រេច÷**

---

[5] សំណើសុំ (E004/2/7) កថាខណ្ឌ ២៤ *ដកស្រង់* យន្តការអន្តរជាតិស្តីពីកេរដំណែលសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍ស្តីពីការចូលមើលកំណត់ហេតុដែលបង្កើតឡើងដោយយន្តការកេរដំណែលអន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ MICT/17/Rev.1 ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៩ មាត្រា ១០(៣)(ខ)។ សំណើសុំ (E004/2/7) កថាខណ្ឌ ២៥ *ដកស្រង់* http://archives.tuolsleng.gov.kh/documents, សេចក្តីប្រកាសបដិសេធការទទួលខុសត្រូវ សំណើសុំ (E004/2/7) កថាខណ្ឌ ២៧-២៩, ៣៦-៩៩, ១០៥។

[6] ឧបសម្ព័ន្ធ ក, ខ, គ, ឃ, ង ភ្ជាប់ជាមួយនឹងសំណើសុំ។

[7] សេចក្តីសម្រេចស្តីពីសេចក្តីណែនាំងសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣ ("សេចក្តីម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ) ("F71/1/1/8")។

**អនុម័ត**សេចក្តីណែនាំទូទៅសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញដូចបានរៀបរាប់នៅក្នុងសេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារសំណុំរឿង ០០២។